ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មការមូលបត្រកម្ពុជា
លេខ: ០០៨/១៩ គ.ម.ក./ប្រ.ក.

# ប្រកាស
## ស្តីពី
## កាតព្វកិច្ចផ្តល់របាយការណ៍ ការជូនដំណឹង និងការស្នើសុំការអនុញ្ញាត របស់ក្រុមហ៊ុនមូលបត្រ និងក្រុមហ៊ុនទីប្រឹក្សាវិនិយោគ

*****

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
## និងជាប្រធាននៃគណៈកម្មការមូលបត្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមូលបត្ររដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ.បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញប្រកាសលេខ ០០៨/១១ គ.ម.ក ប្រ.ក. ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១១ ស្តីពីក្រមសីលធម៌វិជ្ជាជីវៈរបស់ក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារក្រុមហ៊ុនមូលបត្រ

- បានឃើញប្រកាសលេខ ០០៣/១២ គ.ម.ក ប្រ.ក. ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១២ ស្តីពីលក្ខខណ្ឌតម្រូវលើភាពរឹងមាំហិរញ្ញវត្ថុនៃក្រុមហ៊ុនមូលបត្រ
- បានឃើញប្រកាសលេខ០០១/១៨ គ.ម.ក./ប្រ.ក. ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៨ ស្តីពីការផ្តល់អាជ្ញាបណ្ណ និងការគ្រប់គ្រងអាជីវកម្មមូលបត្រ
- យោងតាមការអនុម័តនៃសម័យប្រជុំពេញអង្គរបស់គណៈកម្មការមូលបត្រកម្ពុជា នាថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៨

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-** គោលបំណង

ប្រកាសនេះមានគោលបំណងត្រួតពិនិត្យ និងតាមដាននូវការបំពេញកាតព្វកិច្ចរបស់ក្រុមហ៊ុនមូលបត្រ និងក្រុមហ៊ុនទីប្រឹក្សាវិនិយោគដែលទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតពីគណៈកម្មការមូលបត្រកម្ពុជា (**គ.ម.ក.**)។

**ប្រការ ២.-** គោលដៅ

ប្រកាសនេះមានគោលដៅកំណត់ពីកាតព្វកិច្ចរបស់ក្រុមហ៊ុនមូលបត្រ និងក្រុមហ៊ុនទីប្រឹក្សាវិនិយោគក្នុងការផ្តល់របាយការណ៍ ការជូនដំណឹង និងការស្នើសុំការអនុញ្ញាតជាមុនពីអគ្គនាយកនៃ **គ.ម.ក.** ដោយអនុលោមតាមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន ព្រមទាំងបទប្បញ្ញត្តិដទៃទៀតក្នុងវិស័យមូលបត្រ។

**ប្រការ ៣.-** វិសាលភាព

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះក្រុមហ៊ុនមូលបត្រ និងក្រុមហ៊ុនទីប្រឹក្សាវិនិយោគ ដែលទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតពី **គ.ម.ក.**។

**ប្រការ ៤.-** និយមន័យ

និយមន័យនៃពាក្យបច្ចេកទេសដែលប្រើប្រាស់នៅក្នុងប្រកាសនេះ ត្រូវបានកំណត់នៅក្នុងប្រការនេះ និងមាននៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន ព្រមទាំងមាននៅក្នុងប្រកាសស្តីពីការផ្តល់អាជ្ញាបណ្ណ និងការគ្រប់គ្រងអាជីវកម្មមូលបត្រ និងប្រកាសស្តីពីក្រមសីលធម៌វិជ្ជាជីវៈរបស់ក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារក្រុមហ៊ុនមូលបត្រ។

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាត ឬក្រុមហ៊ុន សំដៅដល់ក្រុមហ៊ុនមូលបត្រ និងក្រុមហ៊ុនទី-

ប្រឹក្សាវិនិយោគដែលទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតពីអគ្គនាយកនៃ **គ.ម.ក.**។

**ការិយាល័យអាជីវកម្ម** សំដៅដល់ទីកន្លែងដែលមានបំពាក់ទៅដោយឧបករណ៍ និងសម្ភារៈគ្រប់គ្រាន់សម្រាប់ធ្វើអាជីវកម្មរបស់ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាត និង/ឬទីកន្លែងដែលអាជីវកម្មរបស់ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតត្រូវបានធ្វើឡើងជាប្រចាំ រួមមាន÷

ក-ទីស្នាក់ការកណ្តាល ជាទីកន្លែងប្រកបអាជីវកម្មចម្បងរបស់ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាត និងជាទីកន្លែងដែលត្រូវបានចុះបញ្ជីថាជាទីស្នាក់ការចុះបញ្ជីស្របតាមច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម។

ខ-សាខាក្រុមហ៊ុន ជាភ្នាក់ងារក្រុមហ៊ុនដើម ហើយពុំមាននីតិបុគ្គលិកលក្ខណៈដាច់ដោយឡែកពីក្រុមហ៊ុនដើមឡើយ និងត្រូវបានចុះបញ្ជីស្របតាមច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្មថាជា "សាខា" ក្រុមហ៊ុន។

**ការផ្លាស់ប្តូរប្រភេទការិយាល័យអាជីវកម្ម** សំដៅដល់ការផ្លាស់ប្តូរការិយាល័យកណ្តាលទៅសាខាក្រុមហ៊ុន ឬការផ្លាស់ប្តូរពីសាខាក្រុមហ៊ុនទៅការិយាល័យកណ្តាល។

**បុគ្គលិកជាន់ខ្ពស់** សំដៅដល់បុគ្គលិកបម្រើការងារនៅក្នុងក្រុមហ៊ុនដែលមានតំណែងចាប់ពីប្រធានផ្នែករហូតដល់នាយកប្រតិបត្តិ រួមទាំងប្រធានភ្នាក់ងារក្រុមហ៊ុនមូលបត្រ ប្រធានប្រតិបត្តិការ បុគ្គលិកជំនាញផ្នែកច្បាប់ និងសវនករផ្ទៃក្នុង។

**បុគ្គលទទួលបានការទទួលស្គាល់គុណវុឌ្ឍិ** សំដៅដល់អភិបាល សហកម្មសិទ្ធិករ នាយកប្រតិបត្តិ ប្រធានប្រតិបត្តិការ ប្រធានភ្នាក់ងារក្រុមហ៊ុនមូលបត្រ និងបុគ្គលិកជំនាញផ្នែកច្បាប់ ដែលទទួលបានការទទួលស្គាល់គុណវុឌ្ឍិពីអគ្គនាយកនៃ **គ.ម.ក.**។

**អនុក្រឹត្យ** សំដៅដល់អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

## ជំពូកទី ២

## ការផ្តល់របាយការណ៍ ការជូនដំណឹង និងការស្នើសុំការអនុញ្ញាត

### ប្រការ ៥.- ការផ្តល់របាយការណ៍ប្រចាំខែ

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតត្រូវផ្តល់ជូន **គ.ម.ក.** នូវរបាយការណ៍ប្រចាំខែដូចខាងក្រោម÷

១-របាយការណ៍លម្អិតអំពីមូលបត្រ មូលនិធិ និង/ឬទ្រព្យសម្បត្តិរបស់អតិថិជននីមួយៗ ដែលក្រុមហ៊ុនរក្សាទុក ដោយអនុលោមតាមមាត្រា ៤៧ នៃអនុក្រឹត្យ។

២-របាយការណ៍ស្តីពីការដោះស្រាយវិវាទ និងពាក្យបណ្តឹងរបស់អតិថិជន។

៣-បញ្ជីគណនីអតិថិជនដែលបានធ្វើបច្ចុប្បន្នកម្ម ដោយបញ្ជាក់ពីអតិថិជនដែលបានបើក និងបិទ

គណនីនៅក្នុងការិយបរិច្ឆេទ។

**ប្រការ ៦**.- ការផ្ដល់របាយការណ៍ប្រចាំត្រីមាស

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតត្រូវផ្ដល់ជូន **គ.ម.ក.** នូវរបាយការណ៍ប្រចាំត្រីមាសដូចខាងក្រោម÷

១-របាយការណ៍ហិរញ្ញវត្ថុប្រចាំត្រីមាសផ្ទៃក្នុង ដែលបានរៀបចំអនុលោមតាមច្បាប់ស្ដីពីគណនេយ្យ និងសវនកម្មជាធរមាន ដោយបង្ហាញរចនាសម្ព័ន្ធប្រាក់ចំណេញឲ្យបានច្បាស់លាស់។

២-របាយការណ៍អំពីការជួញដូរមូលបត្ររបស់ក្រុមហ៊ុន អភិបាល សហកម្មសិទ្ធិករ និងនិយោជិតរបស់ក្រុមហ៊ុន។

៣-បញ្ជីត្រួតពិនិត្យផ្ទៃក្នុង និងការបំពេញកាតព្វកិច្ចតាមការតម្រូវរបស់ច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធ។

៤-របាយការណ៍លម្អិតអំពីនិយោជិត បុគ្គលទទួលបានការទទួលស្គាល់គុណវុឌ្ឍិ និងភ្នាក់ងារទទួលបានអាជ្ញាបណ្ណ ព្រមទាំងការបែងចែកទៅតាមផ្នែកអាជីវកម្មនីមួយៗ។

**ប្រការ ៧**.- ការផ្ដល់របាយការណ៍ប្រចាំឆ្នាំ

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតត្រូវផ្ដល់ជូន **គ.ម.ក.** នូវរបាយការណ៍ប្រចាំឆ្នាំដូចខាងក្រោម÷

១-របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ដែលត្រូវបានធ្វើសវនកម្មរួចដោយសវនករឯករាជ្យ និងដែលបានរៀបចំឡើងដោយអនុលោមតាមច្បាប់ស្ដីពីគណនេយ្យ និងសវនកម្មជាធរមាន។

២-របាយការណ៍សវនកម្ម និងលិខិតផ្សេងៗដែលទទួលបានពីសវនករឯករាជ្យ។

៣-របាយការណ៍អំពីសមិទ្ធផល និងបញ្ហាប្រឈមរបស់ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ ដែលអនុវត្តតាមផែនការអាជីវកម្ម។

៤-កិច្ចសន្យាធានារ៉ាប់រងវិជ្ជាជីវៈ ប្រសិនបើមាន។

៥-រចនាសម្ព័ន្ធបច្ចុប្បន្ននៃក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាត ដោយបញ្ចូលទាំងក្រុមហ៊ុនហូលឌីង/ក្រុមហ៊ុនមេ បុត្រសម្ព័ន្ធ និងសាខាទាំងអស់នៃក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាត។

៦-លិខិតបញ្ជាក់ពីក្រុមហ៊ុនពាក់ព័ន្ធដែលធានាកាតព្វកិច្ចបំណុលនៃក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាត ឬបុត្រសម្ព័ន្ធទាំងអស់របស់ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាត និងឯកសារពាក់ព័ន្ធ ប្រសិនបើមាន។

៧-អង្គការលេខបច្ចុប្បន្នរបស់ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាត។

៨-លិខិតបញ្ជាក់ចុះហត្ថលេខាដោយសវនករឯករាជ្យនៃក្រុមហ៊ុនផ្ដល់សេវាសវនកម្មក្នុងវិស័យមូលបត្រទៅលើមូលបត្រ មូលនិធិ ឬទ្រព្យសម្បត្តិរបស់អតិថិជនអនុលោមតាមចំណុចទី ៧ នៃមាត្រា ៤៧ នៃអនុក្រឹត្យ។

៩-ព័ត៌មានផ្សេងទៀតដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ក.**។

**ប្រការ ៨.- កាលបរិច្ឆេទនៃការផ្តល់របាយការណ៍**

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតត្រូវផ្តល់របាយការណ៍ជូន **គ.ម.ក.** តាមកាលបរិច្ឆេទដូចខាងក្រោម ឬក្នុងរយៈពេលសមស្របណាមួយដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ក.** ÷

១-របាយការណ៍ប្រចាំខែយ៉ាងយូរត្រឹមថ្ងៃទី១០ នៃខែបន្ទាប់។

២-របាយការណ៍ប្រចាំត្រីមាសយ៉ាងយូរត្រឹមថ្ងៃទី១៥ ខែទីមួយនៃត្រីមាសបន្ទាប់។

៣-របាយការណ៍ប្រចាំឆ្នាំយ៉ាងយូរត្រឹមថ្ងៃទី៣១ ខែមីនានៃឆ្នាំបន្ទាប់។

ក្នុងករណីដែលកាលបរិច្ឆេទចែងក្នុងកថាខណ្ឌទី ១ នៃប្រការនេះត្រូវចំថ្ងៃចុងសប្តាហ៍ ឬថ្ងៃឈប់សម្រាកសាធារណៈ ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតត្រូវផ្តល់របាយការណ៍នៅថ្ងៃធ្វើការបន្ទាប់។

**ប្រការ ៩.- ការប្រែប្រួលស្ថានភាពគ្រប់គ្រង និងហិរញ្ញវត្ថុ**

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរជាបន្ទាន់ដល់ **គ.ម.ក.** ក្នុងករណីមានការប្រែប្រួលណាមួយដែលអាចជះឥទ្ធិពលដល់ក្រុមហ៊ុនក្នុងការប្រកបអាជីវកម្មមូលបត្រ ឬដល់អតិថិជនរបស់ក្រុមហ៊ុនដូចខាងក្រោម÷

១-ការប្រែប្រួលខ្លាំងនៃស្ថានភាពគ្រប់គ្រងរបស់ក្រុមហ៊ុន។

២-ការប្រែប្រួលខ្លាំងនៃទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន។

៣-ការប្រែប្រួលខ្លាំងនៃស្ថានភាពឥណទាន ឬបំណុលរបស់ក្រុមហ៊ុន។

៤-ការប្រែប្រួលខ្លាំងនៃស្ថានភាពវិនិយោគរបស់ក្រុមហ៊ុន។

៥-ការប្រែប្រួលខ្លាំងនៃរចនាសម្ព័ន្ធប្រាក់ចំណេញរបស់ក្រុមហ៊ុន។

៦-ការប្រែប្រួលខ្លាំងផ្សេងទៀតដែលពាក់ព័ន្ធនឹងស្ថានភាពគ្រប់គ្រង និងហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។

ការជូនដំណឹងត្រូវរួមបញ្ចូលទាំងការវាយតម្លៃអំពីឥទ្ធិពលនៃការប្រែប្រួលទាំងនោះលើក្រុមហ៊ុន និងអតិថិជនរបស់ក្រុមហ៊ុន ព្រមទាំងសកម្មភាព ឬវិធានការទាំងអស់ដែលក្រុមហ៊ុនធ្វើឡើងដើម្បីគ្រប់គ្រងការប្រែប្រួលនោះ។

**ប្រការ ១០.- ការផ្លាស់ប្តូរប្រព័ន្ធគ្រប់គ្រងហានិភ័យនិងត្រួតពិនិត្យផ្ទៃក្នុង និងផែនការអាជីវកម្ម**

រាល់ការផ្លាស់ប្តូរប្រព័ន្ធគ្រប់គ្រងហានិភ័យ ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងផែនការអាជីវកម្មរបស់ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាត ក្រុមហ៊ុនត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ **គ.ម.ក.** ក្នុងរយៈពេល ៧ (ប្រាំពីរ) ថ្ងៃបន្ទាប់ពីថ្ងៃផ្លាស់ប្តូរ។

**ប្រការ ១១.- ការទាមទារសំណង និងការផ្លាស់ប្តូរកិច្ចសន្យាធានារ៉ាប់រងវិជ្ជាជីវៈ**

ករណីក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាត ធ្វើការទាមទារសំណងក្នុងក្របខ័ណ្ឌកិច្ចសន្យាធានារ៉ាប់រងវិជ្ជាជីវៈ ឬធ្វើការផ្លាស់ប្តូរដែនកំណត់នៃកិច្ចសន្យានោះ ដែលទាក់ទងនឹងអាជីវកម្មទទួលបានអាជ្ញាបណ្ណ/

ការអនុញ្ញាតក្រុមហ៊ុនត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ **គ.ម.ភ.** ក្នុងរយៈពេល ៧ (ប្រាំពីរ) ថ្ងៃបន្ទាប់ពីមានការទាមទារសំណង ឬការផ្លាស់ប្តូរកិច្ចសន្យានោះ។

**ប្រការ ១២.- ការជូនដំណឹងអំពីការប្រព្រឹត្តល្មើស ឬហេតុការណ៍ដែលស្ថិតក្នុងស្ថានភាពពិសេសណាមួយ**

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតត្រូវជូនដំណឹងជាបន្ទាន់ដល់ **គ.ម.ភ.** ប្រសិនបើក្រុមហ៊ុន ក្រុមហ៊ុនមេ បុត្រសម្ព័ន្ធ សាខា ការិយាល័យតំណាង ភ្នាក់ងារទទួលបានអាជ្ញាបណ្ណ ឬបុគ្គលិកជាន់ខ្ពស់របស់ក្រុមហ៊ុនដែលកំពុងបំពេញឬបានបញ្ចប់មុខងារ ដែលក្នុងអំឡុងពេលបំពេញមុខងារនោះបានប្រព្រឹត្តល្មើសនឹងច្បាប់ និងបទប្បញ្ញត្តិជាធរមាន ÷

១-រងការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ មានពិរុទ្ធភាព ឬត្រូវបានផ្តន្ទាទោស ដោយសារការប្រព្រឹត្តល្មើសនឹងច្បាប់ និងបទប្បញ្ញត្តិជាធរមាននៅក្នុងយុត្តាធិការណាមួយ។

២-ជាប់បណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងសកម្មភាពធុរកិច្ច ឬការអនុវត្តវិជ្ជាជីវៈក្នុងវិស័យមូលបត្រនៅក្នុងយុត្តាធិការណាមួយ។

៣-ទទួលរងពិន័យអន្តរការណ៍ ព្យួរ ឬដកហូតអាជ្ញាបណ្ណ/ការអនុញ្ញាត ឬត្រូវបានបដិសេធមិនឲ្យចុះបញ្ជី/អាជ្ញាបណ្ណ/ការអនុញ្ញាត ដោយនិយ័តករ ស្ថាប័នស្វ័យនិយ័តករ ឬអង្គភាពវិជ្ជាជីវៈក្នុងយុត្តាធិការណាមួយ។

**ប្រការ ១៣.- ការផ្លាស់ប្តូរ ឬការកែប្រែព័ត៌មាន**

លើកលែងមានការកំណត់ផ្សេងពីនេះ ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតត្រូវជូនដំណឹងជាបន្ទាន់ដល់ **គ.ម.ភ.** ក្នុងករណីមានការកែប្រែឯកសារ ឬព័ត៌មានសំខាន់ណាមួយដែលបានដាក់ជូន **គ.ម.ភ.** នៅក្នុងពាក្យស្នើសុំ ឬស្នើសុំបន្តអាជ្ញាបណ្ណ/ការអនុញ្ញាត/ការទទួលស្គាល់គុណវុឌ្ឍិ និងឯកសារភ្ជាប់ពាក្យស្នើសុំ ឬស្នើសុំបន្ត។

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតត្រូវស្នើសុំការអនុញ្ញាតជាមុនពីអគ្គនាយកនៃ **គ.ម.ភ.** សម្រាប់រាល់ការផ្លាស់ប្តូរ ឬកែប្រែ ដូចខាងក្រោម÷

១-ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ការទិញក្រុមហ៊ុន ឬការផ្ទេរប្រតិបត្តិការអាជីវកម្ម។

២-ការបង្កើន ឬការបន្ថយដើមទុន។

**ប្រការ ១៤.- ការផ្លាស់ប្តូរ ឬមូលហេតុដែលប៉ះពាល់អាជ្ញាបណ្ណ/ការអនុញ្ញាត**

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ **គ.ម.ភ.** យ៉ាងយូរ ៧ (ប្រាំពីរ) ថ្ងៃនៃថ្ងៃធ្វើការ ក្រោយពេលមានហេតុការណ៍ ឬមូលហេតុណាមួយដែលបណ្តាលឲ្យក្រុមហ៊ុនអាចឈានទៅរកការជម្រះបញ្ជី ការរំលាយក្រុមហ៊ុន ការផ្អាក ឬការបញ្ឈប់អាជីវកម្មមូលបត្រ។

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតត្រូវស្នើសុំការអនុញ្ញាតជាមុនពីអគ្គនាយកនៃ **គ.ម.ភ.** នៅ

ពេលក្រុមហ៊ុនមានបំណងចាប់ផ្តើមការជំរះបញ្ជី ការរំលាយ ការផ្អាក ឬការបញ្ឈប់អាជីវកម្មមូលបត្រ។

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ **គ.ម.ក.** អំពីអវត្តមានពីក្រុមហ៊ុនដោយគ្មានមូលហេតុ ការលាឈប់ ការបញ្ចប់តួនាទី ឬការផ្លាស់ប្តូរមុខងាររបស់បុគ្គលទទួលបានការទទួលស្គាល់គុណវុឌ្ឍិក្នុងរយៈពេល ៧ (ប្រាំពីរ) ថ្ងៃ បន្ទាប់ពីអវត្តមានពីក្រុមហ៊ុនដោយគ្មានមូលហេតុរយៈពេល ៧ (ប្រាំពីរ) ថ្ងៃជាប់ៗគ្នា ឬទទួលបានការជូនដំណឹង ឬលិខិតលាឈប់ពីការងារ ឬការសម្រេចបញ្ចប់តួនាទី ឬការផ្លាស់ប្តូរមុខងាររបស់បុគ្គលនោះ។

**ប្រការ ១៥.-** ការឈប់ធ្វើអាជីវកម្មមូលបត្រ

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតត្រូវស្នើសុំការអនុញ្ញាតពីអគ្គនាយកនៃ **គ.ម.ក.** ដើម្បីឈប់ធ្វើអាជីវកម្មមូលបត្រ ដោយភ្ជាប់មកជាមួយនូវនីតិវិធី និងឯកសារពាក់ព័ន្ធនឹងការឈប់ធ្វើអាជីវកម្មមូលបត្រក្នុងរយៈពេលយ៉ាងតិច ៦ (ប្រាំមួយ) ខែ មុនថ្ងៃឈប់ធ្វើអាជីវកម្ម។ ការឈប់ធ្វើអាជីវកម្ម នីតិវិធី និងរយៈពេលនៃការអនុវត្តនីតិវិធីឈប់ធ្វើអាជីវកម្មត្រូវទទួលការយល់ព្រមពីអគ្គនាយកនៃ **គ.ម.ក.**។ ក្នុងករណីការអនុវត្តនីតិវិធីនៃការឈប់ធ្វើអាជីវកម្មប្រើប្រាស់ពេលលើសពីរយៈពេលទទួលបានការអនុញ្ញាត អគ្គនាយកនៃ **គ.ម.ក.** មានសិទ្ធិកំណត់រយៈពេលបន្ថែម។

ការឈប់ធ្វើអាជីវកម្មមូលបត្រត្រូវអនុវត្តតាមនីតិវិធីដូចមានចែងក្នុងអនុក្រឹត្យស្តីពីបុននីតិសម្បទា និងការជម្រះបញ្ជីក្នុងវិស័យមូលបត្រ ក្នុងករណីជម្រះបញ្ជីដោយស្ម័គ្រចិត្ត។

**ប្រការ ១៦.-** ការបង្កើតបុត្រសម្ព័ន្ធ ឬការិយាល័យទំនាក់ទំនងពាណិជ្ជកម្ម

មុនពេលបង្កើតបុត្រសម្ព័ន្ធ បើក ឬបិទការិយាល័យទំនាក់ទំនងពាណិជ្ជកម្ម ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតត្រូវស្នើសុំការអនុញ្ញាតពីអគ្គនាយកនៃ **គ.ម.ក.** ដោយត្រូវបំពេញលក្ខខណ្ឌដែលកំណត់ដោយ **គ.ម.ក.**។

រាល់របាយការណ៍ដែលក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតត្រូវផ្តល់ជូន **គ.ម.ក.** អនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមានត្រូវរួមបញ្ចូលព័ត៌មានពាក់ព័ន្ធនឹងបុត្រសម្ព័ន្ធ និងការិយាល័យទំនាក់ទំនងពាណិជ្ជកម្មនៅក្នុង និងក្រៅប្រទេស។

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតត្រូវជូនដំណឹងដល់ **គ.ម.ក.** ក្នុងរយៈពេល ៧ (ប្រាំពីរ) ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីទទួលបានការជូនដំណឹងស្តីពីការត្រួតពិនិត្យ ឬការស៊ើបអង្កេត ឬទណ្ឌកម្មនានា ដែលចេញដោយអាជ្ញាធរ ឬតុលាការមានសមត្ថកិច្ចពាក់ព័ន្ធនឹងបុត្រសម្ព័ន្ធ ឬការិយាល័យទំនាក់ទំនងពាណិជ្ជកម្មរបស់ក្រុមហ៊ុន។

**ប្រការ ១៧.-** បុត្រសម្ព័ន្ធ និងក្រុមហ៊ុនហូលឌីង/ក្រុមហ៊ុនមេ

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតត្រូវជូនដំណឹងជាបន្ទាន់ដល់ **គ.ម.ក.** ក្នុងករណីមានចំណុច

ណាមួយដូចខាងក្រោម កើតឡើងចំពោះបុត្រសម្ព័ន្ធ ឬក្រុមហ៊ុនហូលឌីង/ក្រុមហ៊ុនមេនៅក្នុង ឬក្រៅប្រទេស÷

១-ការព្យួរអាជីវកម្ម ការព្យួរ ឬការដកហូតអាជ្ញាបណ្ណ/ការចុះបញ្ជី/ការអនុញ្ញាត។

២-ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ឬការធ្វើអនុប្បទានអាជីវកម្មដោយផ្នែក ឬទាំងស្រុង។

៣-ការហាមឃាត់ ឬការដាក់កំហិតក្នុងការចេញមូលបត្រ។

៤-សេចក្តីសម្រេចរំលាយក្រុមហ៊ុន។

៥-ការចាប់ផ្តើមនៃនីតិវិធីណាមួយទាក់ទងនឹងនីតិវិធីនៃការក្ស័យធន។

៦-រឿងអាស្រូវទាក់ទងនឹងមូលបត្រ ឬការប្រព្រឹត្តល្មើស ឬការទទួលរងការចោទប្រកាន់ពីអំពើល្មើសនឹងច្បាប់ ឬបណ្តឹងតាមផ្លូវច្បាប់។

៧-ករណីផ្សេងទៀតដែលតម្រូវដោយអគ្គនាយកនៃ **គ.ម.ក.**។

## ប្រការ ១៨.- ការជូនដំណឹងអំពីការជួញដូរ

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតត្រូវជូនដំណឹងជាបន្ទាន់ដល់ **គ.ម.ក.** ដោយផ្ទាល់មាត់ ឬមធ្យោបាយផ្សេងទៀតដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ក.** និងជាលាយលក្ខណ៍អក្សរ ករណីការជួញដូររបស់ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាត ឬអភិបាល សហកម្មសិទ្ធិករ និយោជិត និងអតិថិជនរបស់ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាត អាចមាន ឬមានផលប៉ះពាល់ដល់ការប្រព្រឹត្តទៅនៃទីផ្សារមូលបត្រ ឬផលប្រយោជន៍របស់វិនិយោគិនសាធារណៈ។

## ប្រការ ១៩.- របាយការណ៍លើស្ថានភាពនៃការធានាទិញមូលបត្រ

ក្រុមហ៊ុនធានាទិញមូលបត្រត្រូវផ្តល់ជូន **គ.ម.ក.** នូវព័ត៌មានដូចខាងក្រោម÷

១-រាល់អនុស្សរណៈនៃការយោគយល់ និងកិច្ចសន្យាពាក់ព័ន្ធនឹងការធានាទិញមូលបត្រ និង/ឬការធានាទិញមូលបត្របន្ត។

២-ទំហំធានាទិញមូលបត្រជាសាច់ប្រាក់សរុប។

៣-បំណុលសក្តានុពលដែលក្រុមហ៊ុនជំពាក់ភាគីផ្សេងៗ ប្រសិនបើមាន។

៤-ក្រុមហ៊ុនធានាទិញមូលបត្របន្ត ប្រសិនបើមាន។

៥-ភស្តុតាងនៃការធានាទិញមូលបត្របន្ត ប្រសិនបើមាន។

៦-ហានិភ័យនៃការធានាទិញមូលបត្រ។

៧-រាល់ព័ត៌មានទាក់ទងទៅនឹងស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។

ក្រុមហ៊ុនធានាទិញមូលបត្រដែលចុះកិច្ចសន្យាធានាទិញបន្ត ត្រូវផ្តល់ជូន **គ.ម.ក.** នូវព័ត៌មានដូចខាងក្រោម ÷

១-ទំហំធានាទិញមូលបត្របន្តជាសាច់ប្រាក់សរុប។

២- បំណុលសក្ដានុពលដែលក្រុមហ៊ុនជំពាក់ភាគីផ្សេងៗ ប្រសិនបើមាន។

៣- ហានិភ័យនៃការធានាទិញមូលបត្របន្ត។

៤- រាល់ព័ត៌មានទាក់ទងទៅនឹងស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។

ក្រុមហ៊ុនធានាទិញមូលបត្រ និងក្រុមហ៊ុនធានាទិញមូលបត្រដែលចុះកិច្ចសន្យាធានាទិញបន្ត ត្រូវផ្ដល់ជូន **គ.ម.ក.** ក្នុងរយៈពេល ៧ (ប្រាំពីរ) ថ្ងៃនៃថ្ងៃធ្វើការ នូវរបាយការណ៍ និងព័ត៌មានដូចមានចែងក្នុងកថាខណ្ឌទី ១ និងទី ២ នៃប្រការនេះ បន្ទាប់ពីក្រុមហ៊ុនចុះកិច្ចសន្យាធានាទិញមូលបត្រ ឬធានាទិញបន្តជាមួយក្រុមហ៊ុនបោះផ្សាយ និងត្រូវផ្ដល់ជូន **គ.ម.ក.** រៀងរាល់ពេលមានការផ្លាស់ប្ដូរបន្តបន្ទាប់ លើកលែងចំណុចទី ១ នៃកថាខណ្ឌទី ១ នៃប្រការនេះ ដែលក្រុមហ៊ុនត្រូវផ្ដល់ជូន **គ.ម.ក.** ភ្លាមបន្ទាប់ពីក្រុមហ៊ុនបានចុះអនុស្សារណៈយោគយល់ និង/ឬកិច្ចសន្យាពាក់ព័ន្ធ។

## ជំពូកទី ៣
## បទប្បញ្ញត្តិផ្សេងៗ

### ប្រការ ២០.- ការយកចិត្តទុកដាក់ក្នុងការរៀបចំរបាយការណ៍

រាល់របាយការណ៍ និងព័ត៌មានអនុលោមតាមច្បាប់ អនុក្រឹត្យ និងប្រកាសនេះត្រូវរៀបចំឡើងដោយប្រុងប្រយ័ត្ន និងដោយយកចិត្តទុកដាក់ដើម្បីធានាឲ្យបាននូវភាពសុក្រឹត ច្បាស់លាស់ និងពេញលេញ។ ប្រសិនបើមានកំហុសឆ្គង ឬការខ្វះខាតណាមួយត្រូវបានរកឃើញ ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ **គ.ម.ក.** ជាបន្ទាន់ និងត្រូវផ្ដល់សារជាថ្មីនូវរបាយការណ៍ និងព័ត៌មានដែលកែតម្រូវរួច។

### ប្រការ ២១.- កាតព្វកិច្ចផ្ដល់ព័ត៌មាន និងឯកសារតាមការស្នើសុំ

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាត និង/ឬភ្នាក់ងារទទួលបានអាជ្ញាបណ្ណត្រូវផ្ដល់ព័ត៌មាន និងឯកសារពាក់ព័ន្ធផ្សេងៗតាមការស្នើសុំរបស់អគ្គនាយកនៃ **គ.ម.ក.** ដើម្បីកំណត់ពីភាពត្រឹមត្រូវនៃក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាត និង/ឬភ្នាក់ងារទទួលបានអាជ្ញាបណ្ណក្នុងការអនុវត្តតាមច្បាប់ បទប្បញ្ញត្តិ ឬសេចក្ដីណែនាំរបស់អគ្គនាយកនៃ **គ.ម.ក.**។

### ប្រការ ២២.- ទម្រង់នៃរបាយការណ៍ និងការផ្ដល់ព័ត៌មាន

រាល់របាយការណ៍ និងព័ត៌មានអនុលោមតាមប្រកាសនេះត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ឬមធ្យោបាយផ្សេងទៀតតាមការកំណត់របស់អគ្គនាយកនៃ **គ.ម.ក.** និងជាឯកសារថាសទន់ (Soft Copy)។

## ជំពូកទី ៤
## ទោសប្បញ្ញត្តិ

**ប្រការ ២៣.-** ពិន័យអន្តរការណ៍

ដោយមិនទាន់គិតពីទោសទណ្ឌផ្សេងទៀតដូចមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិជាធរមាននៅព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតដែលប្រព្រឹត្តល្មើសនឹងប្រការ ៥, ប្រការ ៦, ប្រការ ៧, ប្រការ ៩, ប្រការ ១០, ប្រការ ១១, ប្រការ ១២, ប្រការ ១៣, ប្រការ ១៤, ប្រការ ១៥, ប្រការ ១៦, ប្រការ ១៧, ប្រការ ១៨, ប្រការ ១៩, ប្រការ ២០, ប្រការ ២១, ប្រការ ២២ ឬផ្តល់ព័ត៌មានខុសដោយចេតនា ឬដោយធ្វេសប្រហែសធ្ងន់ធ្ងរ ឬមិនគោរពតាមការណែនាំ ឬតាមការតម្រូវរបស់អគ្គនាយកនៃ **គ.ម.ក.** ត្រូវទទួលទណ្ឌកម្មរដ្ឋបាលដូចមានចែងនៅក្នុងប្រការ ២៤ នៃប្រកាសនេះ និង/ឬទទួលពិន័យអន្តរការណ៍ពី **គ.ម.ក.** ជាសាច់ប្រាក់មិនលើសពី ២០០.០០០.០០០ (ពីររយលាន) រៀល។

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតដែលយឺតយ៉ាវក្នុងការផ្តល់របាយការណ៍ ការជូនដំណឹង ឬការឆ្លើយតបតាមរយៈពេល ឬកាលបរិច្ឆេទដូចមានកំណត់នៅក្នុងប្រការ ៨, ប្រការ ១០, ប្រការ ១១, កថាខណ្ឌទី ១ និងទី ៣ នៃប្រការ ១៤, កថាខណ្ឌទី ៣ នៃប្រការ ១៦ ឬកថាខណ្ឌទី ៣ នៃប្រការ ១៩ នៃប្រកាសនេះ ត្រូវទទួលទណ្ឌកម្មរដ្ឋបាលដូចមានចែងនៅក្នុងប្រការ ២៤ នៃប្រកាសនេះ និង/ឬពិន័យអន្តរការណ៍ពី **គ.ម.ក.** ជាសាច់ប្រាក់ដូចខាងក្រោម៖

១- ចំនួន ១.០០០.០០០ (មួយលាន) រៀលក្នុងមួយថ្ងៃ ចំពោះការយឺតយ៉ាវក្នុងការផ្តល់របាយការណ៍ ឬការជូនដំណឹងជូន **គ.ម.ក.**។

២- ចំនួន ៤០០.០០០ (បួនរយពាន់) រៀលក្នុងមួយថ្ងៃ ចំពោះការយឺតយ៉ាវក្នុងការឆ្លើយតប ឬការផ្តល់ព័ត៌មានផ្សេងៗជូន **គ.ម.ក.**។

**ប្រការ ២៤.-** ទណ្ឌកម្មរដ្ឋបាល

ទណ្ឌកម្មរដ្ឋបាលមានដូចខាងក្រោម៖

១- ព្រមាន។

២- ដឹកនាំកែតម្រង់។

៣- ព្យួរ ឬបណ្តេញចេញពីមុខតំណែងនូវអភិបាល និង/ឬបុគ្គលិកជាន់ខ្ពស់។

៤- ដាក់កំហិតលើអាជ្ញាបណ្ណ/ការអនុញ្ញាត។

៥- ព្យួរ ឬដកហូតអាជ្ញាបណ្ណ/ការអនុញ្ញាត។

## ជំពូកទី ៥
## អវសានប្បញ្ញត្តិ

**ប្រការ ២៥.-** គោលការណ៍ណែនាំ

អគ្គនាយកនៃ **គ.ម.ក.** អាចចេញគោលការណ៍ណែនាំស្របតាមច្បាប់ អនុក្រឹត្យ និងប្រកាសនេះដើម្បីសម្រួលដល់ការយល់ដឹង និងការអនុវត្ត។

**ប្រការ ២៦.-** បដិវាទកម្ម

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ ២៧.-** ការអនុវត្ត

អគ្គនាយកនៃ **គ.ម.ក.** ប្រធាននាយកដ្ឋានត្រួតពិនិត្យអន្តរការីមូលបត្រ ប្រធាននាយកដ្ឋានកិច្ចការគតិយុត្ត គ្រប់ប្រធាននាយកដ្ឋាន-អង្គភាពស្ថិតនៅចំណុះឱ្យ **គ.ម.ក.** និងបុគ្គលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ៦រោច ខែអស្សុជ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ តុលា ឆ្នាំ២០១៨

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**និងជាប្រធាននៃគណៈកម្មការមូលបត្រកម្ពុជា**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងយុត្តិធម៌
- ធនាគារជាតិនៃកម្ពុជា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- ដូចប្រការ ២៧
  "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ